# កម្មវត្ថុ៖សំណើរដាក់គំរោងផ្គត់ផ្គង់សេវាបោះពុម្ព Offset Printing ជូនចំពោះទីភ្នាក់ងារបោះពុម្ព

ធនាគារABAគឺជាគ្រឹះស្ថានធនាគារឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា។ដោយបានបង្កើតឡើងនៅឆ្នាំ១៩៩៦ដែលមានឈ្មោះថា Advanced Bank of Asia Limited ធនាគារ ABA កាលពីដំបូងត្រូវបានបង្កើតឡើងដើម្បីផ្តល់សេវាធនាគារពាណិជ្ជដល់អតិថិជនសាជីវកម្មមួយចំនួននិងផ្តល់សេវាធនាគារពេញលេញដល់ប្រជាជនកម្ពុជាមកពីគ្រប់មជ្ឈដ្ឋាន។បច្ចុប្បន្ននេះយើងមានសាខាសរុបចំនួន២៥នៅទូទាំងប្រទេសកម្ពុជាហើយកំពុងតែបន្តពង្រីកសាខាបន្ថែមទៀត។
ដើម្បីឆ្លើយតបនឹងតម្រូវការអតិថិជនសំខាន់ៗរបស់យើងដែលត្រូវការសេវាធនាគារដ៏ល្អប្រសើរបច្ចុប្បន្ននេះយើងកំពុងស្វែងរកអ្នកផ្គត់ផ្គង់ដែលមានជំនាញច្បាស់លាស់ដើម្បីផ្តល់សេវាបោះពុម្ពដែលមានលក្ខណៈសម្បត្តិពិសេសនិងតម្លៃសមរម្យ។
យើងសូមស្នើឲ្យក្រុមហ៊ុនរបស់លោកអ្នកចូលរួមក្នុងការដាក់សំណើផ្គត់ផ្គង់សេវាបោះពុម្ពOffset ដល់ធនាគាររបស់យើង។

## ពេលវេលា

| ព័ត៌មានលម្អិត | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|
| ចេញលិខិតស្នើសុំឲ្យដាក់សំណើ | ថ្ងៃទី៣១ខែមករា ឆ្នាំ២០១៥ | ០៨:០០ ព្រឹក |
| ចុះឈ្មោះ និងការដាក់ជូនសំណើ (បញ្ជាក់លក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុ) | ថ្ងៃទី០៥ខែកុម្ភៈ ឆ្នាំ២០១៥ | ត្រឹមម៉ោង៥:០០ ល្ងាច |
| ការដាក់ជូនលក្ខខណ្ឌតម្រូវ សម្ភាសន៍ កាលបរិច្ឆេទ ត្រួតពិនិត្យសម្ភារ | ថ្ងៃទី០៦ - ០៩ ខែកុម្ភៈឆ្នាំ២០១៥ | តាមការណាត់ជួប |
| ការវាយតម្លៃ/សេចក្តីជូនដំណឹង អំពីថ្ងៃប្រកាសឈ្មោះក្រុមហ៊ុនជ្រើសរើសក្នុងវគ្គចុងក្រោយ | ថ្ងៃទី១០ខែកុម្ភៈ ឆ្នាំ២០១៥ | ១០:០០ព្រឹក |
| កាលបរិច្ឆេទប្រគល់កិច្ចសន្យា (ប៉ាន់ស្មាន) | ថ្ងៃទី១២ខែកុម្ភៈ ឆ្នាំ២០១៥ | តាមការណាត់ជួប |

## លក្ខណៈសម្បត្តិ៖

ភ្នាក់ងារ/អ្នកផ្គត់ផ្គង់សេវាបោះពុម្ពដែលមានចំណាប់អារម្មណ៍ត្រូវមានបទពិសោធន៍ក្នុងអាជីវកម្មយ៉ាងតិចចំនួន៥ឆ្នាំនិងជាភ្នាក់ងារ/អ្នកផ្គត់ផ្គង់ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

## លក្ខខណ្ឌតម្រូវនិងនីតិវិធីចុះឈ្មោះ៖

1. ក្រុមហ៊ុនបោះពុម្ពដែលមានចំណាប់អារម្មណ៍សូមបំពេញនិងដាក់ទម្រង់ចុះឈ្មោះអំពីព័ត៌មានក្រុមហ៊ុនសំណៅចម្លងលិខិតចុះបញ្ជីពាណិជ្ជកម្ម (សូមមើលទម្រង់ដែលភ្ជាប់មកជាមួយ)។
2. ទម្រង់ចុះឈ្មោះត្រូវចុះហត្ថលេខាដោយបុគ្គលមានសិទ្ធិនៅក្នុងការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុនឬអង្គភាពសាជីវកម្មនិងក្នុងការពិភាក្សាប្រសិនបើចាំបាច់នៅពេលចេញឯកសារកិច្ចស

Head office:
# 148, Preah Sihanouk Blvd., Sangkat
Boeung Keng Kang I, Khan Chamkarmon,
Phnom Penh, Kingdom of Cambodia.
Tel: 855 23225333 Fax: 855 23216333
Email: info@ababank.com
P.O.Box: 2277 SWIFT: ABAAKHPP

ន្យាដែលបានពីលិខិតស្នើនេះ(RFP)។

3. ក្រុមហ៊ុនបោះពុម្ពត្រូវបង្ហាញឈ្មោះអតិថិជនចម្បងយ៉ាងតិចចំនួន៥ដែលបានប្រើប្រាស់សេវាយ៉ាងទៀងទាត់ឬបានប្រើប្រាស់សេវានៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយដែលរួមមានឈ្មោះក្រុមហ៊ុនបរិមាណនិងប្រភេទសេវាដែលបានផ្គត់ផ្គង់ ព្រមទាំងឯកសារកិច្ចសន្យាផងដែរ។
4. ទម្រង់ចុះឈ្មោះសារតារក្រុមហ៊ុនសំណៅចម្លងលិខិតចុះបញ្ជីពាណិជ្ជកម្មត្រូវដាក់ជូនរួមជាមួយនឹងលក្ខខណ្ឌតម្រូវផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ។

## នីតិវិធីដាក់ពាក្យ

1. ផ្តល់គំរូឯកសារបោះពុម្ព (ដែលក្រុមហ៊ុនលោកអ្នកបានផ្គត់ផ្គង់ជូនអតិថិជន) ដែលស្រដៀងគ្នានឹងវត្ថុធាតុដើមនិងផលិតផលសម្រេចដូចមានរៀបរាប់នៅក្នុងលក្ខខណ្ឌតម្រូវផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ។
2. ផ្តល់វត្ថុធាតុដើមចាំបាច់ដែលក្រុមហ៊ុនលោកអ្នកនឹងផ្គត់ផ្គង់ជូនយើងខ្ញុំ។
3. ផ្តល់សម្រង់តម្លៃតាមលក្ខខណ្ឌដែលបានបង្ហាញតម្លៃសម្រង់ត្រូវមានសុពលភាពនៅក្នុងរយៈពេល៦ខែ។
4. គំរូឯកសារនៅក្នុងចំណុចទី១ត្រូវមានបិទឲ្យបានត្រឹមត្រូវ និងដាក់នៅក្នុងស្រោមសំបុត្របិទជិតដោយមានសរសេរថាៈឯកសារគំរូទី១។
5. គំរូឯកសារនៅក្នុងចំណុចទី២ត្រូវមានបិទឲ្យបានត្រឹមត្រូវ និងដាក់នៅក្នុងស្រោមសំបុត្របិទជិតដោយមានសរសេរថាៈឯកសារគំរូទី២។
6. សម្រង់តម្លៃតាមលក្ខខណ្ឌខាងក្រោមត្រូវដាក់នៅក្នុងស្រោមសំបុត្របិទជិតដោយមានសរសេរថាៈសម្រង់តម្លៃ។
7. គំរូឯកសារទី១គំរូឯកសារទី២និងគំរូឯកសារទី៣ត្រូវដាក់នៅក្នុងស្រោមសំបុត្រដែលមានទំហំធំជាង (ទំហំ A៣ឬ A២) ត្រូវបិទជិតដោយមានសរសេរឈ្មោះក្រុមហ៊ុនបោះពុម្ពរួចផ្ញើមកផ្នែកទីផ្សារនៃធនាគារABA សូមមើលឯកសារភ្ជាប់និងទីតាំង។

## លក្ខណៈវិនិច្ឆ័យវាយតម្លៃ

a. ហិរញ្ញវត្ថុ/តម្លៃទាបជាងគេ ៤០%
b. បច្ចេកទេស/គុណភាពវត្ថុធាតុដើម ៤០%
c. សារតារ/ព័ត៌មានក្រុមហ៊ុន ១០%
d. សម្ភារ ១០%

## នីតិវិធីវាយតម្លៃ

គណៈកម្មាធិការផ្ទៃក្នុងមួយនឹងត្រូវបង្កើតឡើងដែលជ្រើសរើសចេញពីផ្នែករដ្ឋបាលនិងទីផ្សារ។សំណើទាំងអស់ត្រូវបើកនិងធ្វើការវាយតម្លៃនៅក្នុងពេលតែមួយនៅចំពោះមុខគណៈកម្មាធិការ។រាល់ព័ត៌មានដែលបានដាក់ជូនទាំងអស់ត្រូវចាត់ទុកជាព័ត៌មានសម្ងាត់។ធនាគារសូមរក្សាសិទ្ធិក្នុងការបដិសេធសំណើណាមួយឬទាំងអស់ឬធ្វើការប្រគល់កិច្ចសន្យាជូនអ្នកដាក់សំណើណាមួយដែលផ្តល់អត្ថប្រយោជន៍ខ្ពស់បំផុតសម្រាប់ក្រុមហ៊ុនដោយពុំចាំបាច់ធ្វើការពិភាក្សាឬចរចាបន្ថែមឡើយ។អ្នកដាក់សំណើត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការរៀបចំសំណើរបស់ខ្លួនទៅតាមទម្រង់ដែលបានកំណត់។